# ព័ត៌មានប្រជាសាស្ត្រ និងសេដ្ឋកិច្ច របស់ពលករចំណាកស្រុក*

CDRI
Cambodia Development Resource Institute
សង្ខេប គោលនយោបាយរហ័ស
ទស្សនទានសម្រាប់ការឆ្លើយតបខាងគោលនយោបាយ

## ១) ទិដ្ឋភាពទូទៅ

បន្ទាប់ពីការផ្ទុះអំពើហិង្សា នៅតាមព្រំដែនប្រទេសកម្ពុជា-ថៃ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ មានពលករចំណាកស្រុកប្រមាណ ៩១ម៉ឺននាក់ បានវិលត្រលប់មកស្រុកវិញ គិតត្រឹមថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ជាមួយនឹងការបាត់បង់ប្រភពចំណូលសំខាន់ៗរបស់ពួកគេ។ ព័ត៌មានច្បាស់លាស់នៃប្រជាសាស្ត្រ និងសេដ្ឋកិច្ចរបស់ពលករដែលត្រលប់មកវិញទាំងនេះ គឺមានសារៈសំខាន់ សម្រាប់ការចាត់វិធានការគាំទ្រទាន់ពេលវេលា និងមានប្រសិទ្ធភាព។

## ២) ព័ត៌មានសង្ខេប

- តាមការប៉ាន់ប្រមាណថា មានពលករចំណាកស្រុកខ្មែរ ប្រហែល ១,១លាននាក់ កំពុងធ្វើការនៅក្នុងប្រទេសថៃ។ ការប៉ាន់ស្មាននេះ គឺផ្អែកលើ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) នៅឆ្នាំ២០២៣។ ប៉ុន្តែ ចំនួនពិតប្រាកដនៃពលករចំណាកស្រុក អាចមានច្រើនជាងនេះ បើគណនាចំនួនគ្រួសារពលករខ្មែរ ដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃទាំងអស់។

### ព័ត៌មានពលករ

- **ភេទ៖** ប្រុស ៥០,៨% ស្រី ៤៩,២%
- **អាយុ៖** ៩៦% មានអាយុចន្លោះពី ១៨ ដល់ ៤០ឆ្នាំ
- **ការអប់រំ៖** ភាគច្រើនមានកម្រិតការសិក្សាផ្លូវការទាប
  - ៥៧% មានការសិក្សាកម្រិតបឋមសិក្សា
  - ៣៦% មានការសិក្សាកម្រិតមធ្យមសិក្សា
  - ៤,៣% មិនបានចូលរៀន
  - <១% មានការសិក្សាកម្រិតឧត្តមសិក្សា ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ

- **ទីតាំងប្រភពដើម៖** ពលករចំណាកស្រុកដែលត្រលប់មកវិញ ជាង ៧០% មកពីខេត្តជាប់ព្រំដែនប្រទេសថៃ ដូចជា បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ ឧត្តរមានជ័យ និងប៉ៃលិន (រូបភាពទី១)។

រូបភាពទី១៖ របាយទីតាំងភូមិសាស្ត្រប្រភពដើមរបស់ពលករចំណាកស្រុក




ប្រភព៖ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២៣

- **ប្រាក់ផ្ញើមកផ្ទះ៖** ការធ្វើចំណាកស្រុកទៅប្រទេសថៃ មានភាពងាយស្រួលជាពិសេសពី ខេត្តបន្ទាយមានជ័យ និងបាត់ដំបង។ ទោះជាយ៉ាងណា ប្រាក់ផ្ញើមកផ្ទះប្រចាំឆ្នាំ ក្នុងសមាជិកម្នាក់ពីប្រទេសថៃ គឺមិនច្រើនជាងប្រាក់ផ្ញើសម្រាប់អ្នកធ្វើការក្នុងស្រុកប៉ុន្មានទេ នៅថៃបានផ្ញើ ៦៥០ដុល្លារអាមេរិក នៅក្នុងស្រុកបានផ្ញើ ៤៥០ដុល្លារអាមេរិក។ ផ្ទុយទៅវិញ ពលករខ្មែរមួយចំនួនតូច ដែលធ្វើចំណាកស្រុកទៅប្រទេសកូរ៉េ បានផ្ញើច្រើនជាងខ្លាំងដល់ ៣.០០០ដុល្លារអាមេរិកក្នុងសមាជិកម្នាក់។

- **មុខរបរកន្លងមក៖** ពួកគេទៅធ្វើការនៅក្នុងវិស័យសំណង់ (៤២%) ច្រើនជាងវិស័យផ្សេងៗទៀត ដូចជា កសិកម្ម (១៥%) សេវាកម្ម (១២%) និងកម្មន្តសាល (៨%) នៅប្រទេសថៃ (រូបភាពទី២)។

- គ្រួសារចំណាកស្រុកប្រហែល ៣០% ស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនេះបើយោងតាមការប៉ាន់ស្មានភាពក្រីក្រ ដោយផ្អែកលើទិន្នន័យការចំណាយប្រើប្រាស់របស់គ្រួសារនៃ CSES។ ទិន្នន័យនេះ ច្រើនជាងជិតពីរដងនៃអត្រាមធ្យមភាគភាពក្រីក្រថ្នាក់ជាតិដែលមាន ១៩%។ បើសិនពួកគេត្រលប់មកវិញ គ្មានការងារ និងប្រាក់ចំណូល ហើយមកបន្ថែមបន្ទុកលើ ចំណាយការប្រើប្រាស់ក្នុងគ្រួសារទៀត អត្រាភាពក្រីក្រនៅក្នុងចំណោមគ្រួសារចំណាកស្រុក អាចឡើងដល់ប្រមាណ ៥០% (រូបភាពទី៣)។

រូបភាពទី២៖ ស្ថិតិកម្មករចំណាកស្រុកតាមភេទ និងវិស័យ




ប្រភព៖ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២៣

រូបភាពទី៣៖ ការបែងចែកនៃការចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ មុន និងបន្ទាប់ពីត្រលប់មកវិញ ធៀបនឹងបន្ទាត់ភាពក្រីក្រ




ប្រភព៖ CSES ២០២៣ និងការប៉ាន់ស្មានរបស់អ្នកនិពន្ធផ្អែកលើការវិភាគដង់ស៊ីតេនៃការចំណាយប្រើប្រាស់

## ៣) បញ្ហាប្រឈម

- ត្រឹមថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (MLVT) បានរាយការណ៍ថា ឱកាសការងារដែលមានស្រាប់ មានចំនួនប្រហែល ១៩ម៉ឺនកន្លែង នៅទូទាំងប្រទេសកម្ពុជា ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។
- ការងារដែលមានប្រមាណ ៨០% ប្រមូលផ្ដុំនៅក្នុង ៦ខេត្ត ដែលការធ្វើចំណាកស្រុកផ្ទៃក្នុងមានកម្រិតខ្ពស់ស្រាប់ គឺកំពង់ស្ពឺ រាជធានីភ្នំពេញ ស្វាយរៀង កណ្ដាល កំពង់ឆ្នាំង និងតាកែវ។ ដោយឡែកក្នុងខេត្តកំណើតរបស់ពលករចំណាកស្រុក បែរជាមានការងារតិចតួចប៉ុណ្ណោះ មានន័យថា **ចំនួនការងារមិនគ្រប់គ្រាន់ទេនៅតាមខេត្តកំណើតរបស់ពួកគេ** (រូបភាពទី៤)។
- **នេះមានន័យថា មានពលករប្រហែល ៧២ម៉ឺននាក់ អាចនឹងនៅគ្មានការងារ ធ្វើក្រោយត្រលប់មកវិញ។**
- បន្ទុកលើសម្ពាធសេដ្ឋកិច្ចគ្រួសារ ដែលមានសមាជិកធ្វើចំណាកស្រុក ៣១% កំពុងមានបំណុលមធ្យមប្រមាណ ៥.០០០ដុល្លារអាមេរិក ខណៈដែលប្រាក់ផ្ញើមកផ្ទះកន្លងមក គឺមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់ទេ។
- ចំនួនពលករច្រើនជាងពាក់កណ្ដាល ធ្លាប់តែធ្វើការក្នុងវិស័យសំណង់ និងកសិកម្ម តែបច្ចុប្បន្ននេះ វិស័យទាំងនេះ កំពុងមានតម្រូវការកម្លាំងពលកម្មតិចតួចនៅក្នុងទីផ្សារការងារក្នុងស្រុក។ បញ្ហា**ខុសជំនាញ**នេះ ជាបញ្ហាមួយទៀតបន្ថែមទៅលើបញ្ហាទីផ្សារការងារនៅខុសតំបន់របស់ពលករចំណាកស្រុករស់នៅផងដែរ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អាសយដ្ឋាន៖ #៥៦ ផ្លូវ ៣១៥ ទួលគោក ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ cdri@cdri.org.kh
គេហទំព័រ៖ www.cdri.org.kh
ទូរសព្ទ៖ +៨៥៥ ២៣ ៨៨១៧១០/៨៨១៩១៦/៨៨៣៦០៣

រូបភាពទី៤៖ ប្រៀបធៀបការងារមានស្រាប់ និងអ្នកចំណាកស្រុកត្រលប់មកវិញ នៅតាមខេត្តនានា




ប្រភព៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២៣

## ៤) ដំណោះស្រាយខាងគោលនយោបាយ

- ប្រសិនបើពលករចំណាកស្រុកត្រលប់មកវិញ ជាង ៩១ម៉ឺននាក់ រកបានការងារក្នុងស្រុកបាន នោះវានឹងមានផលជះវិជ្ជមានទៅលើផលិតផលសរុបក្នុងស្រុក ដោយបង្កើនកម្លាំងពលកម្មបានជិត ១០% បន្ថែមទៀត។
- បញ្ហាទីតាំងឱកាសការងារ នៅខុសពីតំបន់ដែលពលករចំណាកស្រុករស់នៅ មានន័យថា ការសម្របសម្រួលការចំណាកស្រុកក្នុងប្រទេស គឺជាមូលដ្ឋានសំខាន់មួយនៃយុទ្ធសាស្ត្រឆ្លើយតប។
- ដើម្បីគាំទ្រពលករចំណាកស្រុកត្រលប់មកវិញ ជាពិសេស ពលករដែលមានជំនាញទាប ប្រាក់វិនិយោគរបស់ធីវ៉េត (TVET) អាចប្រើសម្រាប់ធ្វើការបណ្ដុះបណ្ដាលរយៈពេលខ្លី។ ការធ្វើដូចនេះ នឹងផ្ដល់ពេលវេលា រង់ចាំឱ្យទីផ្សារការងារថ្មីបង្កើតបានគ្រប់គ្រាន់ ព្រមគ្នានឹងការអភិវឌ្ឍជំនាញរបស់ពលករ ដែលនឹងបង្កើនសក្ដានុពលសេដ្ឋកិច្ចរយៈពេលវែង។
- គ្រួសារចំណាកស្រុក ៣០% គឺរស់នៅក្នុងភាពក្រីក្រ និងជាប់បំណុល។ ប្រសិនបើគ្មានការគាំពារសង្គមទេ ការមិនមានការងារក្នុងពេលភ្លាមៗនេះ នឹងធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេកាន់តែពិបាកឡើង។ រាជរដ្ឋាភិបាលអាចពិចារណាកំណត់ និងផ្ដល់អាទិភាព ផ្ដល់ជំនួយដល់គ្រួសារទាំងនេះ តាមរយៈប័ណ្ណក្រីក្រ។ កម្មវិធីផ្ដល់ការងារធារណៈដល់គ្រួសារពលករក្រីក្រនៅតាមទីជនបទជាលក្ខណៈបណ្ដោះអាសន្ន អាចជាជម្រើសជំនួស ឬជាការបំពេញបន្ថែមដល់ការផ្ដល់ជំនួយជាសាច់ប្រាក់។
- ពលករចំណាកស្រុកមានបទពិសោធន៍ខាងកសិកម្មពីប្រទេសថៃដែលចង់បន្តការងារក្នុងវិស័យនេះ តែមិនចង់ធ្វើស្រែដូចមុនទេ ដោយសារផ្ដល់ប្រាក់ចំណូលមិនគ្រប់គ្រាន់ ពួកគេមានជម្រើសពីរយ៉ាងគឺ៖
  - **បង្កើតមុខរបរផ្ទាល់ខ្លួន៖** គ្រួសារចំណាកស្រុក ១០–២០% នៅក្នុងខេត្តជាប់ព្រំដែនដែលមានចំណាកស្រុកច្រើនជាងគេ មានដីចន្លោះពី ១–២ហិកតា ឬច្រើនជាងនេះ (តារាងទី១)។ សម្រាប់គ្រួសារទាំងនេះ ការធ្វើកសិកម្មដែលមានតម្លៃខ្ពស់ ដូចជា ដាំបន្លែ និងផ្លែឈើ គឺជាជម្រើសដែលអាចអនុវត្តបាន។
  - **ធ្វើការងារក្នុងប្រព័ន្ធ៖** សម្រាប់សមាជិកក្រុមគ្រួសារពលករចំណាកស្រុក ៨០% ដែលមានដីម្នាក់តិចជាងមួយហិកតា ពួកគេគួរតែធ្វើការងារក្នុងប្រព័ន្ធ ក្នុងវិស័យឧស្សាហកម្ម កសិកម្មពាណិជ្ជកម្ម ឬការកែច្នៃផលិតផលកសិកម្ម។ ទោះជាយ៉ាងណា កិច្ចសហការគ្នា រវាងរាជរដ្ឋាភិបាល និងវិស័យឯកជន គឺជាការចាំបាច់ ដើម្បីបង្កើតឱកាសការងារទាំងនេះ។

តារាងទី១៖ ទំហំដីកសិកម្មក្នុងសមាជិកម្នាក់នៃគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក

| ខេត្ត | ពលករចំណាកស្រុកដែលត្រលប់មកវិញ | ចំនួនប្រជាជនដែលព្យាករ | <១% ហ.ត/សមាជិក | ១-៥ ហ.ត/សមាជិក |
|---|---|---|---|---|
| បន្ទាយមានជ័យ | ៣៣៩.២៤៨ | ៩៧៤.៩៣៤ | ៧៦,៧% | ២៣,៣% |
| បាត់ដំបង | ២២៤.៤០៦ | ១.១៣១.៣០៨ | ៨៩,៤% | ១០,៦% |
| ឧត្តរមានជ័យ | ២៨.១៨៣ | ៣១៧.៣៩១ | ៩០,១% | ៩,៩% |
| ព្រះវិហារ | ៣.៦៥៨ | ២៩៥.៦៩២ | ១០០,០% | ០,០% |
| ប៉ៃលិន | ៩.៥៤៦ | ៨៥.៧៦០ | ៧២,០% | ២៨,០% |
| សរុប | ៦០៥.០៤១ | ២.៨០៥.០៨៥ | - | - |

ប្រភព៖ ការព្យាករស្ថិតិប្រជាជនកម្ពុជាឆ្នាំ២០២០-២០៣៣ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២៣។

**កំណត់សម្គាល់៖ សង្ខេបគោលនយោបាយហ័សនេះ គឺជាផ្នែកនៃរបាយការណ៍ស្រាវជ្រាវមួយដោយសហការស្រាវជ្រាវជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។*